County of Los Angeles
DEPARTMENT OF
PUBLIC SOCIAL SERVICES

# ច្បាប់ក្រមសីលធម៌

## សំរាប់អតិថិជន/ភ្ញៀវរបស់ខោនធី




ក្រសួងសង្គមកិច្ចសាធារណៈ (DPSS) ខិតខំយ៉ាងខ្លាំងក្នុងការលើកកំពស់វប្បធម៌នៃការគោរពគ្នា រវាងអតិថិជន/ភ្ញៀវ និង បុគ្គលិក។ ការិយាល័យ DPSS ប្រឹងប្រែងបង្កើតបរិយាកាសដែលមានសន្តិសុខ និងសុវត្ថិភាពសម្រាប់និយោជិក បុគ្គលិកសន្តិសុខ និងភ្ញៀវរបស់ខ្លួន។ បុគ្គលណាដែលចូលមកទីកន្លែង ឬហៅទូរស័ព្ទមកការិយាល័យDPSS មិនត្រូវបង្កបញ្ហា ធ្វើឱ្យរំខានដល់កិច្ចការ ឬ ចូលជ្រៀតជ្រែកដោយផ្ទាល់ជាមួយការអនុវត្តន៍ការងារផ្លូវការ និងកាតព្វកិច្ចរបស់បុគ្គលិក DPSS ឡើយ។

បុគ្គលណាដែលចូលមកទីកន្លែង ឬ ហៅទូរស័ព្ទមកការិយាល័យ DPSS និងបានរំខានធ្វើឱ្យខូចសណ្តាប់ធ្នាប់ដូចខាងក្រោម អាចត្រូវបានអមដំណើរឱ្យចាកចេញពីការិយាល័យសម្រាប់ថ្ងៃនោះ ឬ ការហៅទូរស័ព្ទរបស់ពួកគេត្រូវបានបញ្ចប់ទោះបីជាពួកគេមិនទាន់បានបញ្ចប់ការងារផ្លូវការរបស់ពួកគេ ក៏ដោយ។ ស្ថិតក្នុងស្ថានការណ៍បែបនេះ អតិថិជន/ភ្ញៀវនឹងត្រូវបានផ្តល់នូវជម្រើសសេវាកម្មជំនួស ដូចជា ការហៅទូរស័ព្ទទៅមជ្ឈមណ្ឌលសេវាកម្មអតិថិជន និងសេវាកម្មអនឡាញតាមគេហទំព័រ BenefitsCal ។

## ឥរិយាបថរំខានរួមមាន៖

- ការធ្វើការគំរាមកំហែង (ដោយពាក្យសម្តី/អកប្បកិរិយា)
- ការប្រើភាសាមិនសមរម្យ
- ការបង្ហាញកាយវិការមិនសមរម្យទៅកាន់បុគ្គលិកខោនធី ឬភ្ញៀវផ្សេង ៗទៀត
- ការប្រើអំពើហឹង្សា ឬព្យាយាមប្រើអំពើហឹង្សាទៅកាន់បុគ្គលិកខោនធី ឬភ្ញៀវផ្សេង ៗទៀត
- ការបង្កជម្លោះ ឬបំផ្លាញសម្ភារៈ
- ការស្តោះទឹកមាត់ ការបោះទឹកនោមបាចសាច ការទាត់ធាក់ ការខាំ ឬការចូលរួមក្នុងការប្រព្រឹត្តអំពើហិង្សាដូចគ្នាណាមួយ
- ការថតរូប ឬការថតវីដេអូរបស់បុគ្គលិកខោនធី ឬភ្ញៀវផ្សេង ៗទៀត
- ការចូលទៅកាន់ ឬព្យាយាមចូលទៅកន្លែងដែលហាមឃាត់
- ការបំផ្លាញ ឬ ធ្វើឱ្យខូចបែកបាក់ទ្រព្យសម្បត្តិរបស់ខោនធី
- ការប៉ះពាល់អ្នកផ្សេងដោយមិនមានការអនុញ្ញាតពីពួកគេ ឬ
- ការរារាំងដល់ការឆ្លងកាត់ដោយសេរីរបស់បុគ្គលិកខោនធី បុគ្គលិកសន្តិសុខ ឬភ្ញៀវផ្សេង ៗទៀត

## ការផាកពិន័យដែលអាចកើតឡើងសំរាប់ការបំពានច្បាប់ក្រមសីលធម៌:

ការបង្កបញ្ហាដោយចេតនា ឬការបង្កបញ្ហាម្តងហើយម្តងទៀតដែលត្រូវបានហាមប្រាមដោយច្បាប់ ឬដែលល្មើសនឹងច្បាប់ក្រមសីលធម៌ អាចនាំឱ្យមានផលវិបាកនៃលទ្ធផលមួយ (1) ឬផលវិបាកច្រើនដែលបណ្តាលឱ្យមានលទ្ធផលដូចខាងក្រោម ៖

- ការមិនគោរពតាមការព្រមានផ្ទាល់មាត់ អាចនាំឱ្យមានផលវិបាកដោយត្រូវបានគេស្នើសុំឱ្យចាកចេញពីការិយាល័យសម្រាប់ថ្ងៃនោះ ឬ ការហៅទូរស័ព្ទរបស់ពួកគេត្រូវបានបញ្ចប់។
- ការធ្វើអន្តរាគមន៍ពីភ្នាក់ងារអនុវត្តច្បាប់ ដែលរួមមានការចាប់ខ្លួនដែលអាចកើតឡើង និងការផ្តន្ទាទោសផ្នែករដ្ឋប្បវេណី ឬការផ្តន្ទាទោសផ្នែកព្រហ្មទណ្ឌ។ ច្បាប់ផ្នែកព្រហ្មទណ្ឌវគ្គលេខ 422 (a), 594 (a), និង វគ្គលេខ 602.1 (b) ។

CAMBODIAN